ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :............០៣០/១៩............**ក.ប**/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង
## ស្តីពី
## មណ្ឌលប្រឡងជ្រើសរើសក្របខណ្ឌ
## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩

**យោង** ៖ សេចក្តីជូនដំណឹងលេខ ០១៩/១៩ ក.ប/ស.ជ.ណ.រ.ប.ប ចុះថ្ងៃអង្គារ ៨រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ឆ្នាំ២០១៩។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បេក្ខជន បេក្ខនារីទាំងអស់ឱ្យបានជ្រាបថា មណ្ឌលប្រឡងជ្រើសរើសក្របខណ្ឌថ្មីឆ្នាំ២០១៩ គឺនៅមណ្ឌល "**វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ**" ស្ថិតនៅតាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី *ជាប់នឹងរបងវត្តទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។*

**<u>បញ្ជាក់៖</u>**

- បញ្ជីឈ្មោះបេក្ខជន បេក្ខនារី នឹងបិទផ្សាយនៅថ្ងៃព្រហស្បតិ៍ ទី៥ ខែកញ្ញា ឆ្នាំ២០១៩ នៅមណ្ឌលប្រឡង (**វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ**) និងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វេលាម៉ោង ១០:០០ព្រឹក
- បេក្ខជន បេក្ខនារី ត្រូវមកដល់មណ្ឌលប្រឡងនៅថ្ងៃសុក្រ ទី៦ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង៦:០០ព្រឹក
- **ករណីបេក្ខជន បេក្ខនារីមកយឺត១៥នាទីក្រោយពីចែកវិញ្ញាសាប្រឡង មិនអនុញ្ញាតឱ្យប្រឡងឡើយ**
- ករណីបេក្ខជន បេក្ខនារីខកខានមិនបានគោរពទៅតាមការកំណត់ខាងលើនេះ គណៈកម្មការប្រឡងក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមិនទទួលខុសត្រូវលើការបាត់បង់បេក្ខភាពប្រឡងឡើយ។

អាស្រ័យហេតុនេះ សូមបេក្ខជន បេក្ខនារីទាំងអស់អនុវត្ត និងជ្រាបជាព័ត៌មាន៕

ថ្ងៃ ចន្ទ ៤ កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**